**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ៣៣១...ស.ស.ស./ព្រ.ប.ស

ថ្ងៃព្រហស្បតិ៍ ០៥កើត ខែ ចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៨.

# ប្រកាស

## ស្តីពី

## លក្ខខណ្ឌក្នុងការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៦១ សនរប.ប្រក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៧ ស្តីពីការអនុវត្តន៍អនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល ។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

# សម្រេច

**ប្រការ១ .–**

ប្រកាសនេះមានគោលបំណងការពារសុខភាពរបស់ទារក និងកុមារ និងកំណត់លក្ខខណ្ឌក្នុងការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ដើម្បីធានាឱ្យបាននូវការប្រើប្រាស់ផលិតផលទាំងនេះឱ្យបានសមស្រប និងមានសុវត្ថិភាព។

**ប្រការ២ .–**

ប្រកាសនេះមានគោលដៅគ្រប់គ្រងការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមាររបស់គ្រឹះស្ថានផលិត គ្រឹះស្ថាននាំចូល និងអ្នកចែកចាយផលិតផលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៣ .–**

ប្រកាសនេះមានវិសាលភាពអនុវត្តលើការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ .–**

ការផ្សព្វផ្សាយ ៖ សំដៅដល់គ្រប់ទង្វើរបស់ផលិតករ អ្នកនាំចូល អ្នកចែកចាយដែលមានលក្ខណៈឃោសនាពាណិជ្ជកម្មតាមគ្រប់រូបភាព។

**ប្រការ៥ .–**

ម្ចាស់គ្រឹះស្ថានផលិត អ្នកនាំចូល អ្នកចែកចាយ ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារនៅក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង) ។

**ប្រការ៦ .–**

សំណុំឯកសារស្នើសុំការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារមានដូចខាងក្រោម ៖

- ពាក្យស្នើសុំ (ចំនួន០៣ច្បាប់)
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- ប័ណ្ណពន្ធប៉ាតង់
- វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សិប្បកម្ម (ផលិតផលក្នុងស្រុក)

- ឯកសារសម្រាប់ផ្សព្វផ្សាយ (ចំនួន១០ច្បាប់)

- ផលិតផលគំរូដែលត្រូវផ្សព្វផ្សាយ (ចំនួន០២ឯកតា)

- GMP / HACCP Certificate ពីប្រទេសផលិត

- Free Sale Certificate / Health Certificate

- ឯកសារពាក់ព័ន្ធផ្សេងៗ

**ប្រការ៧ .-**

ការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារតាមរយៈវិទ្យុ ទូរទស្សន៍ គេហទំព័រ បណ្តាញសង្គម សារព័ត៌មាន ទស្សនាវដ្តី ខិត្តប័ណ្ណ(Leaflet) ប័ណ្ណប្រកាសរូបភាព(Poster) ផ្ទាំងប៉ាណូ សិក្ខាសាលា តាំងពិព័រណ៌ ស្លាកយីហោ និងតាមគ្រប់រូបភាពផ្សេងៗទៀត អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

**ប្រការ ៨.-**

ហាមដាច់ខាតផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារតាមគ្រប់រូបភាពនៅក្នុង ឬជុំវិញបរិវេណខាងក្រៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន។

**ប្រការ៩ .-**

លិខិតរបស់ក្រសួងសុខាភិបាល ដែលអនុញ្ញាតឱ្យផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារតាមៈ

- ទស្សនាវដ្តី វិទ្យុ គេហទំព័រ បណ្តាញសង្គម សារព័ត៌មាន ឯកសារផ្សព្វផ្សាយផ្សេងៗ ផ្ទាំងរូបភាព(Poster), ផ្ទាំងរូបភាពបញ្ឈរ (Standing poster) សម្ភារផ្សព្វផ្សាយផ្សេងៗ ឬមធ្យោបាយផ្សព្វផ្សាយផ្សេងៗ មានសុពលភាព០៦ខែ (ប្រាំមួយខែ) និងមានលេខកូដសម្គាល់របស់ក្រសួងសុខាភិបាល (xxxxxxxxxx@ddf )។

- ប្រតិទិន ខិត្តប័ណ្ណ ផ្ទាំងប៉ាណូ ប្រអប់ភ្លើងដាក់តាមទីសាធារណៈ ផ្ទាំងប៉ាណូប្រើអគ្គិសនី (LED) មានសុពលភាព០១ឆ្នាំ (មួយឆ្នាំ) និងមានលេខកូដសម្គាល់របស់ក្រសួងសុខាភិបាល (xxxxxxxxxx@ddf)។

- សិក្ខាសាលា ប្រជុំគុមូល ឬស្តង់ផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ អាចប្រព្រឹត្តទៅតាមការស្នើសុំរបស់ក្រុមហ៊ុន (មានរយៈពេលមិនលើសពី០១ខែ)។

**ប្រការ១០ .-**

ក្រសួងសុខាភិបាលនឹងផ្តល់លិខិតអនុញ្ញាតឱ្យផ្សព្វផ្សាយផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ក្នុងរយៈពេលអតិបរមា ២០ ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ ។

**ប្រការ១១ .-**

ក្នុងករណីដែលរកឃើញ ឬមានការប្រកាសអាសន្នពីអាជ្ញាធរមានសមត្ថកិច្ចថាផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារនោះមានការប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ដល់ទារក និងកុមារ ក្រសួងសុខាភិបាលមានសិទ្ធិដកហូតយកមកវិញនូវលិខិតអនុញ្ញាតដែលចេញដោយក្រសួងសុខាភិបាល។

ក្នុងករណីនេះម្ចាស់គ្រឹះស្ថានផលិត អ្នកនាំចូល អ្នកចែកចាយផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវប្រមូលត្រឡប់មកវិញនូវផលិតផលទាំងនោះដោយម្ចាស់ការ ឬសហការជាមួយក្រសួងសុខាភិបាល ឬក្រសួងពាក់ព័ន្ធ។

**ប្រការ១២ .-**

ម្ចាស់គ្រឹះស្ថានផលិត អ្នកនាំចូល អ្នកចែកចាយផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវបង់ប្រាក់សេវាដែលកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រសួងសុខាភិបាល ។

**ប្រការ១៣ .-**

ម្ចាស់គ្រឹះស្ថានផលិត អ្នកនាំចូល អ្នកចែកចាយផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ដែលបានប្រព្រឹត្តិល្មើសផ្ទុយនឹងខ្លឹមសារដូចមានចែងក្នុងប្រកាសនេះ ត្រូវពិន័យអន្តរកាលតាមប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រសួងសុខាភិបាល ។

**ប្រការ១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥ .-**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ប្រធាននាយកដ្ឋានមន្ទីរពេទ្យ និងប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

សាស្ត្រាចារ្យ **ឆា-គ្រួយ**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី (ដើម្បីជ្រាបជាព័ត៌មាន)
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ (ដើម្បីសហការ)
- សាលារាជធានី ខេត្ត
- ដូចក្នុងប្រការ១៥
  (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ និងកាលប្បវត្តិ